

# ថ្ងៃទី ៥ កក្កដា ឆ្នាំ ១៩៨៧

**សេរីការ**

អន្តរាគមន៍ផ្ទាល់ នៃអង្គការសហប្រជាជាតិ នៅស្រុកខ្មែរ នៅទស្សវត្សរ៍ ៩០ វាគ្រាន់តែបាន បញ្ចប់សង្គ្រាមអាវុធពិតមែន តែមិនបាន រំលើងកងទ័ពកុម្មុយនិស្តយួន នៅក្នុងដែនដីខ្មែរ ដែលជាឧបសគ្គចំបងដើម្បីអោយប្រជាពលរដ្ឋខ្មែរអាចនឹងសំរេចដោយខ្លួនឯង លើជោគវាសនាខ្លួន ដូចមានគ្រោង នៅក្នុងកិច្ចព្រមព្រៀងសន្តិភាព ២៣ តុលាឆ្នាំ១៩៩១ ព្រោះ កងទ័ពនេះឯង ជាកម្លាំងគាំទ្រគណបក្សប្រជាជនកម្ពុជា ដែលជាបក្សរណបយួន មិនព្រមទទួលស្គាល់លទ្ធផល នៃការបោះឆ្នោតនៅឆ្នាំ ១៩៩៣ ថែមទាំង គំរាមបង្កើត ដំបន់អបគមន៍។ ឧនភាព នៃប្រតិកម្ម (déficit de réaction) របស់អង្គការសហប្រជាជាតិ គឺ ការបណ្តោយអោយ សម្តេចសីហនុ ជ្រើសយកដំណោះស្រាយនៃសិថិលភាព (compromis) ជាមួយបក្សប្រជាជនកម្ពុជា ដែលជាដំណោះស្រាយមួយផ្ទុយពីឆន្ទៈ នៃប្រជាពលរដ្ឋខ្មែរ។ កម្មវិបាកនៃសេចក្តីអនុម័តនេះ គឺ នាំអោយមានកើតរដ្ឋប្រហារ នៅឆ្នាំ ១៩៩៧ បង្កឡើងដោយបក្សប្រជាជនកម្ពុជា ដែលមានកងទ័ពយួន លាក់ខ្លួននៅក្នុងកងទ័ពបក្ស ជាអ្នកវាយប្រហារកងទ័ពសីហនុនិយម ដឹកនាំដោយ ទ្រង់ រណឫទ្ធិ។ រដ្ឋប្រហារនេះ ពង្រា ដំណើរ ឲស្តាក់ស្ទើរអស់ នៃសេចក្តីសង្ឃឹម របស់ប្រជាពលរដ្ឋខ្មែរលើ ការរំដោះស្រុកខ្លួនអោយចេញផុតពីអនុត្តរភាព

(hégémonie) នៃយួន។ មែនទែន ថ្ងៃទី៥ កក្កដា ឆ្នាំ ១៩៩៧ ជាជោគជ័យថ្មី នៃកងទ័ពយួននៅកម្ពុជា ដែលមានតម្លៃលើសពីថ្ងៃទី៧ មករា ឆ្នាំ ១៩៧៩ ទៅទៀត ព្រោះសហគមន៏អន្តរជាតិនាំគ្នាបិទភ្នែក នៅចំពោះមុខ ការបំពានកិច្ចព្រមព្រៀងសន្តិភាព ២៣ តុលា ឆ្នាំ ១៩៩១ ជាលើកទី២ ពីសំណាក់កងទ័ពយួនប្លមជាយោធា នៃភាគីបក្សប្រជាជន និងទុករដ្ឋប្រហារ ថ្ងៃទី៥ កក្កដា ជាវិបត្តិនយោបាយរវាងខ្មែរនិងខ្មែរ។ ដូច្នេះ ថ្ងៃទី៥ កក្កដា ឆ្នាំ ១៩៩៧ ជាថ្ងៃដែលយួន ប្រស់ថ្ងៃទី ៧ មករា អោយមានជីវិតរស់ឡើងវិញ ហើយតទៅមុខ ខ្មែរត្រូវទុកជាទិវា សំរាប់គបស្នងគុណប្រចាំជាតិ ដល់កងទ័ពយួន ។ យួនគេទុកថ្ងៃទី៥ កក្កដា ជា បទឧក្រិដ្ឋអវិរុទ្ធ (crime parfait) របស់គេ ដែលគ្មានតុលាការណា អាចចោទប្រកាន់គេថា ជាអ្នកប្រព្រឹត្តបាននោះឡើយ សូម្បីចិនកុម្មុយនិស្ត តាំងខ្លួនជាអ្នកការពារស្តេចសីហនុក៏ធ្វើព្រងើយនឹងទង្វើរបស់យួននេះដែរ។ ការណ៏នេះ បង្ហាញអោយឃើញថា ចិន និង យួន គេប្រគប់គ្នា ដើម្បី ការពារលទ្ធិកុម្មុយនិស្ត នៅស្រុកខ្មែរ អោយរស់ជានិច្ច ទោះបី គេមានទំនាស់នឹងគ្នា លើរឿងអ្វីផ្សេងៗទៀត នៅក្នុងកំរិតណា ក៏ដោយ។ ដូច្នេះ ថ្ងៃទី៥ កក្កដា ឆ្នាំ ១៩៩៧ ជាទ្វេវិជយ: របស់ ចិន/យួន កុម្មុយនិស្ត លើកម្លាំងខ្មែរ អ្នកជាតិនិយមផង និង លោកសេរីផង៖ កម្ពុជា ពេលក្រោយថ្ងៃទី៥ កក្កដា ក្លាយជា ដែនដីស្ថិតនៅក្រោមឥទ្ធិពល ចិន/យួន កុម្មុយនិស្ត ដោយមានការទទួលស្គាល់ជាតុណ្ហី ពីសំណាក់ ពួកមហាអំណាចលោកសេរី ក្នុងនាមនយោបាយប្រាកដនិយម (realpolitik)។ មួយវិញទៀត ថ្ងៃជ័យ

របស់យួនកុម្មុយនិស្តនេះ វាលុបចោល នូវប្រវត្តិតស៊ូអ្នកស្នេហាជាតិខ្មែរ ប្រឆាំងនឹងយួនក្រហម ក្នុងអំឡុងពេលជាង ពីរទស្សវត្សរ៍ (១៩៧០-១៩៩១) និង រំលស់ នូវតម្លៃ កិច្ចព្រមព្រៀងសន្តិភាព ២៣តុលា ឆ្នាំ ១៩៩១ អោយនៅត្រឹមតែជាតម្លៃក្រដាសតែប៉ុណ្ណោះ ចំពោះអ្នកដឹកនាំយួន។ នៅពេលណា លោក ហ៊ុនសែន គាត់និយាយតាមយួនអោយស្ញប់ថា បក្សប្រជាជនកម្ពុជា ជាអ្នកស្ថាបនានៃសន្តិភាពនៅស្រុកខ្មែរ គឺនៅក្នុងន័យថាសន្តិភាពនេះ ចំពោះយួន ដែលជាចៅហ្វាយរបស់គាត់ គេមិនឈរលើកិច្ចព្រមព្រៀងសន្តិភាព ២៣តុលា នោះទេ ព្រោះគេទុកវាជា ការភាយចេញ ពីជ័យជំនះនៅថ្ងៃទី៥ កក្កដា វិញទេ ដែលជា មូលដ្ឋានមាំទាំពិត សំរាប់ ទ្រទ្រង់សន្តិភាព ត្បិតជា សន្តិភាព នៃបក្សកុម្មុយនិស្តឥណ្ឌូចិននៅកម្ពុជា។ ដូច្នេះ សន្តិភាពមាននៅស្រុកខ្មែរសព្វថ្ងៃ មិនមែនជា សន្តិភាព ដើម្បី ប្រជាពលរដ្ឋខ្មែរនោះទេ ក៏ប៉ុន្តែ វាជា សន្តិភាពមាន បក្សកុម្មុយនិស្តយួនជាម្ចាស់។ អ៊ីតើ[1] ចំពោះខ្មែរយើង ? តែនៅមានអ្នកស្នេហាជាតិ មិនព្រមចុះចាញ់ ដូចករណី សពមហាបុរស កែម ឡីលោកសុខចិត្ត បូជាជីវិតលោក ដើម្បីដាស់ស្មារតីកូនខ្មែរ ឲតស៊ូប្រឆាំងនឹងអំណាចយួននៅស្រុកខ្មែរ ដើម្បី សង្គ្រោះប្រជាជាតិខ្មែរ ដោយកូនខ្មែរ ដើម្បី ពលរដ្ឋខ្មែរ រស់ជា ពលរដ្ឋម្ចាស់ស្រុក។
កូនខ្មែរយើងសង្ឃឹមជានិច្ចថាមរណភាពមហាបុរសកែមឡីនឹងបង្កើត នូវប្រភាព (pouvoir) នៃព្រលឹងខ្មែរ ដើម្បី រំដោះប្រជា

[1] អ៊ីតើ, en serait-il ainsi (pour les Khmers) ?

ជាតិខ្មែរពី អាណានិគមយួន និងរំលើង ក្រុមណាដែលបំរើប្រយោជន៍យួន ដោយប្រើច្បាប់ជាតិកើតចេញពី កិច្ចព្រមព្រៀងសន្តិភាព ២៣ តុលា និងច្បាប់អន្តរជាតិ មាននៅក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ ជាមធ្យោបាយ។ ខ្មែរយើងអាចធ្វើបានព្រោះទង្វើនេះ មិនមែនជាការណ៍ហួសវិស័យ (utopie) នោះឡើយ ទោះបីយើងដឹងថា វិនាដកម្មខ្មែរសព្វថ្ងៃ វាមិនមែនជាអាទិភាព របស់នគរមហាអំណាចទាំងឡាយ តែវាជាករណីយកិច្ចរបស់ពលរដ្ឋខ្មែរ ដូច្នេះបើ គនុជខ្មែរ[2] នាំគ្នាក្រោកឈរឡើងរួមគ្នា ប្រកបដោយប្រណិធិ ប្រើសិទ្ធិខ្លួនជាពលរដ្ឋប្រទល់នឹងអំណាចផ្តាច់ការគ្រប់ប្រភព តាមច្បាប់ តាមសីលធម៌ ច្បាស់ជាវិរយៈនេះ នឹងមានផលដល់ ប្រជាជាតិខ្មែរជាពុំខាន។ នៅក្នុងកាលៈទេសៈសព្វថ្ងៃនេះ យុវជនខ្មែរត្រូវយកការតស៊ូរំដោះជាតិពីអាណានិគមយួនជា គោលចរិតជាតិ ដូចយួនយកមហិច្ឆិតាលេបទឹកដីខ្មែរ ជានយោបាយជាតិយួន។ សង្គ្រាមខ្មែរប្រឆាំងនឹង អាណានិគមយួនសព្វថ្ងៃ ត្រូវកូនខ្មែរទុកវាជាសង្គ្រាមអហិង្សា នៃតម្លៃជាតិខ្មែរ ប្រឆាំងនឹង មហិច្ឆិតាពិជិតរដ្ឋ (ambition d’annexion territoriale) ម៉ឺនឆ្នាំ របស់យួនចំពោះប្រទេសជិតខាងខ្លួន ដែលយួន ទុកមហិច្ឆិតានេះ ជាតម្លៃនៃជាតិយួន។ ដូច្នេះ សង្គ្រាមខ្មែរនឹងយួនលើកនេះជា សង្គ្រាម នៃតម្លៃជាតិមួយទល់នឹងតម្លៃជាតិមួយទៀត។ តែខ្មែរយើងដឹងថា ការតស៊ូខ្មែរជាការប្រយុទ្ធជាធម្មានុរូប ព្រោះជាសមរកម្មនៃការការពារ

[2] គនុជខ្មែរ ; កូនខ្មែរទាំងប្រុសទាំងស្រី។

ជាតិ  រីឯ  ការប្រយុទ្ធយួន វិញ ជាការឈ្លានពានទឹកដីបរទេស និងជានយោបាយ  បំបាត់ជាតិសាសន៍ខ្មែរ  ដូច្នេះជាសង្គ្រាម រវាង អ្នកជា នឹងចោរ។ សួរថាតើចោរជាអ្នកឈ្នះឬ ?ការណ៏នេះ វាអាស្រ័យទៅលើអាកប្បកិរិយារបស់អ្នកជា  បើ អ្នកជា ជាជនកំសាក  និងជាអត្តទត្តបុគ្គល ស្មាញទ្រា (empêtré)  នៅក្នុងអំពើទុច្ចរិត គឺវាពិតជាចោរជា អ្នកឈ្នះ តែបើអ្នកជា ជាខ្មែរមាន ឪត្តប្ប (attitude scrupuleuse) ជាអ្នកស្នេហាជាតិ គឺវាពិតជាចោរជាអ្នកចាញ់។ ការប្រទល់មុខគ្នា រវាង  ខ្មែរនឹងយួន  លើកនេះ  វាជាបញ្ហា  (enjeux)  មួយសំខាន់ណាស់  សំរាប់អាយុជីវិតប្រជាជាតិខ្មែរ ព្រោះ  បើខ្មែរចាញ់ គឺស្រុកខ្មែរបច្ចុប្បន្ន  នឹងក្លាយជាកម្ពុជាក្រោមទី២ជាពុំខាន ដូច្នេះខ្មែរយើងត្រូវមានកាតព្វកិច្ចជាអ្នកឈ្នះ ដើម្បីសង្គ្រោះជាតិពីហានិភ័យយួនម៉ឺនឆ្នាំ។